# ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា

## កិច្ចការស្រាវជ្រាវ

**មុខវិជ្ជា៖ ភាសាវិទ្យា**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់៖ អក្សរសាស្ត្រខ្មែរ ជំនាន់២**

**និស្សិត៖ ភិក្ខុ នួន សារ៉េត**

ព.ស.២៥៦៧ គ.ស.២០២៣

# មាតិកា

ក. និយមន័យ
ខ. អត្ថប្រយោជន៍
គ. ភាសាវិទ្យា
ឃ. មែកធាងវប្បធម៌-អរិយធម៌
ង. សេចក្ដីសន្និដ្ឋាន
ច. ឯកសារយោង

## ក. និយមន័យ

ដូចម្តេចដែលហៅថា "អក្សរសាស្ត្រ" ?

អក្សរសាស្ត្រ គឺជាវិជ្ជាអក្សរក្បួនប្រាប់វិធីនៃអក្សរក្នុងការសរសេរឱ្យបានត្រឹមត្រូវ ភាសាណាមួយ ឬមានន័យថា អក្សរគឺជាក្បួនខ្នាតរឺជាវិជ្ជាមួយ សិក្សាអំពីរបៀប និង វិធីប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដើម្បីបង្ហាញសតិអារម្មណ៍ លាតត្រដាងមនោសញ្ចេតនា ទស្សនៈ និងក៏កត់ត្រាទុកជាប្រវត្តិសាស្ត្រ ដោយរៀបចំតាក់តែងពាក្យពេចន៍ឱ្យពិរោះ ធ្វើឱ្យអ្នកអានជក់ចិត្ត មានអារម្មណ៍ហាក់ដូចជាស្ថិតនៅក្នុងព្រឹត្តការណ៍នៃរឿងទាំងនោះជាប់ជានិច្ច។ ដូច្នេះអក្សរសាស្ត្រ គឺការផ្សព្វផ្សាយមនោសញ្ចេតនា បណ្តុះគំនិត បង្កើតការអប់រំមនុស្ស ខាងស្មារតី និងសតិអារម្មណ៍ ក៏ដូចជាបណ្តុះនូវសីលធម៌ដែរ ។

អក្សរសាស្ត្រ ចែកជាមែកធាងចំនួន ៣ អក្សរសិល្ប៏១, ភាសាវិទ្យា១, អរិយធម៌១ ។

## ២. អត្ថប្រយោជន៍

-នឹងបានយល់ដឹងអំពីអក្សរសាស្ត្រខ្មែរតាមសម័យកាលផ្សេងៗ

-ទទួលបានបទពិសោធន៍ក្នុងមេរៀននេះ

-ចូលរួមចំណែកថែរក្សាអក្សរសាស្ត្រខ្មែរ

-នឹងទទួលបានយល់ដឹងអំពីវប្បធម៌-អរិយធម៌របស់ខ្មែរ

-នឹងបានជាមេរៀនក្នុងអត្ថបទនេះ ឬអាចជាអត្ថបទសម្រាប់ស្រាវជ្រាវពីជំនាន់មួយទៅជំនាន់មួយ

-អក្សរសាស្ត្រមានតួនាទីប្លុកសរុប និង កត់ត្រាបណ្ដាបាតុភូតនានារបស់សង្គមមនុស្ស នូវគំនិតជឿនលឿន អន់ថយរបស់របបសង្គម ក្នុងសម័យកាលនីមួយៗ។

## គ. ភាសាវិទ្យា

វិទ្យាសាស្ត្រដែលសិក្សាអំពីភាសា។ បញ្ញត្តិប្រើក្នុងភាសាវិទ្យាមានពីរ គឺ៖

១. ភាសាវិទូ
២. អ្នកភាសាវិទ្យា។

**១.១ ភាសាវិទ្យាមានមែកធាងសំខាន់ៗដូចជា៖**

(១). សូរវិទ្យា (ការបង្កើតសូរ) (សរីរសទ្ទវិទ្យា,កលសទ្ទវិទ្យា,សោតសទ្ទវិទ្យា)
(២). សទ្ទតាវិទ្យា (ឯកតានៃសូរ)
(៣). រូបសព្ទវិទ្យា (ធាតុនៃការបង្កើតពាក្យ)
(៤). សម្ព័ន្ធវិទ្យា (កន្សោមពាក្យ ល្បះ)
(៥). ន័យវិទ្យា (ន័យនៅក្នុងភាសា ន័យរបស់ពាក្យ ឬល្បះ)
(៦). ប្រាម៉ាទិក (បរិបទនៃការប្រើប្រាស់ភាសា)
(៧). សង្គមភាសាវិទ្យា (ភាសាដែលប្រើប្រាស់ក្នុងសង្គម)
(៨). ភាសាវិទ្យាអនុវត្តន៍...។

# មែកធាងវប្បធម៌-អរិយធម៌



## ឃ. មែកធាងវប្បធម៌-អរិយធម៌

១.២ អរិយធម៌ ចែកជាពីរ៖

១.វប្បធម៌

២.សង្គមធម៌ ។

១.៣ វប្បធម៌ ចែកជាបី៖

(១).ចំណេះដឹង

- -ជំនឿ
- -លិទ្ធិសាសនា
- -សីលធម៌
- -វិទ្យាសាស្ត្រ ។

(២).ការផ្សាយៈ

-សិល្បៈ គំនូរ កុន ល្ខោន តន្ត្រី

-អក្សរសិល្ប៍ (រឿងប្រលោមលោក រឿងព្រេង, កំណាព្យ...)

-អក្សរសាស្ត្រ (អក្សរសិល្ប៍,(១) ភាសាវិទ្យា, អរិយធម៌)

-ពត៌មាន ទូរទស្សន៍ កាសែត ។

---

(១) ទិដ្ឋភាពអក្សរសិល្ប៍មានបី ទ្រឹស្ដីអក្សរសិល្ប៍, ប្រវត្តិអក្សរសិល្ប៍, រិះគន់អក្សរសិល្ប៍ ។

(៣). **អនុវត្តន៍៖**

-ទំនៀមទំលាប់ ប្រពៃណី

-ការសិក្សា

-ការអប់រំកាយ ចិត្ត បញ្ញា ឆន្ទៈ

-ច្បាប់ផ្សេងៗ ។

## ១.៤ សង្គមធម៌ ចែកជាបី៖

**(១). សំភារៈសង្គមៈ**

-ឧបករណ៍សង្គម
-ប្រដាប់តិចនិច
-មុខរបររិជ្ជាជីវៈ ។

**(២). របបសង្គមៈ**

-សេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម

-សង្គមកិច្ច អប់រំ សន្តិសុខ សុខភាព ការងារ
-នយោបាយៈ ក្នុងប្រទេស ក្រៅប្រទេស ។

(៣). **ទំរង់សង្គមៈ**

-ស្ថលសង្គម
-វណ្ណៈសង្គម
-ស្ថាប័នសង្គម
-រដ្ឋប្រជាជាតិ ។

## ១. សេចក្តីសន្និដ្ឋាន៖

កិច្ចការស្រាវជ្រាវនេះ មានការសិក្សា និងបានត្រួតពិនិត្យច្បាស់លាស់ចេញពីឯកសារផ្សេងៗ ខ្ញុំសង្ឃឹមថា នឹងបានជាឯកសារសម្រាប់ជំនួយដល់សិក្ខាកាមទាំងឡាយ ដែលកំពុងសិក្សា និងកំពុងស្វែងរកចំណេះដឹងផ្នែកភាសាខ្មែរ។

ច. ឯកសារយោង៖

- បទបង្ហាញរបស់បណ្ឌិត ឈិន សីហា
- បទបង្ហាញរបស់បណ្ឌិត ស៊ីម សេង
- និងឯកសារបណ្តាញសង្គម

សូមអរព្រះគុណ និង អរគុណ